ខែឧសភា ឆ្នាំ2020

# លំនៅដ្ឋានសម្រាប់មនុស្សចាស់នៅទីក្រុងឡុងប៊ិច

## លំនៅដ្ឋានដែលមានតម្លៃសមរម្យសម្រាប់មនុស្សចាស់





## ការអភិវឌ្ឍន៍លំនៅដ្ឋានសម្រាប់មនុស្សចាស់ថ្មីមួយ

Mercy Housing California (MHC) កំពុងស្នើសុំធ្វើការអភិវឌ្ឍន៍គេហដ្ឋានដែលមានគុណភាពខ្ពស់និងតម្លៃសមរម្យសម្រាប់មនុស្សចាស់ដែលមានចំណូលទាប និងអតីតយុទ្ធជនដែលមានវ័យចំណាស់ដែលគ្មានផ្ទះសម្បែង។ ការអភិវឌ្ឍន៍ ដែលស្ថិតនៅកែងផ្លូវល្បឿនលឿន Pacific Coast Highway (PCH) និងវុក្ខវិថី Martin Luther King Jr. Avenue នៅក្នុងទីក្រុងឡុងប៊ិច នឹងបម្រើជូនមនុស្សចាស់ដែលមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ មានអាយុចាប់ពី 62ឆ្នាំឡើងទៅ និងមានរួមបញ្ចូលនូវទីកន្លែងមនោរម្យជាច្រើនដូចជាទីធ្លាធំទូលាយ ទីតាំងកម្សាន្តកន្លែងអង្គុយលេងនៅខាងក្នុងអគារ ទីធ្លាសហគមន៍ ការគ្រប់គ្រងអចលនទ្រព្យនៅទីតាំង កម្មវិធីផ្តល់សេវាកម្មលំនៅដ្ឋាន ដែលមានបុគ្គលិកខិតខំបម្រើការងារដើម្បីជួយដល់មនុស្សចាស់ និងអតីតយុទ្ធជនដែលមានវ័យចំណាស់ និងមានកន្លែងបម្រើសេវាសហគមន៍នៅជាន់ផ្ទាល់ដី។ ការរចនាអគារនឹងត្រូវបានរួមបញ្ចូលនូវធាតុផ្សំសិល្ប:សាធារណ:ដែលឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្រដ៏សម្បូរបែបនៅក្នុងតំបន់។ អ្នករស់នៅជិតខាង និងសមាជិកសហគមន៍ផ្សេងៗទៀតនឹងត្រូវបានអញ្ជើញឲ្យចូលរួមក្នុងដំណើរការរចនាដ៏រឹងមាំដើម្បីបង្កើតសិល្ប:សាធារណ:នេះ។ ជាចុងក្រោយ ទីតាំងនេះគឺជាមជ្ឈមណ្ឌលនៃមធ្យោបាយដឹកជញ្ជូនសាធារណ: ហាងលក់ទំនិញ បណ្ណាល័យ និងឧទ្យានសាធារណ:។




**901-941 E. PACIFIC COAST HIGHWAY LONG BEACH, CA 90806**

### Mercy Housing California គឺជាម្ចាស់គម្រោងអភិវឌ្ឍន៍លំនៅដ្ឋានដ៏មានបទពិសោធន៍បំផុតប្រចាំរដ្ឋ ដែលមានផ្តល់សេវាកម្មជាច្រើននៅទីតាំងដល់មនុស្សចាស់ដែលឯករាជ្យ។

**MERCY HOUSING CALIFORNIA កំពុងប្រតិបត្តិការ**

**48** សម្រាប់មនុស្សចាស់ សហគមន៍

និងលើសពីនេះ

**3,400** សម្រាប់មនុស្សចាស់ អ៊ីផាតម៉ិន

**ប្រភេទអចលទ្រព្យ**
សម្រាប់មនុស្សចាស់

**ចំនួន**
68

**ទំនាក់ទំនង**
Mandalyn Mendoza
213.743.5824
mandalyn.mendoza@mercyhousing.org

## ការប្តេជ្ញាចិត្តចូលរួមក្នុងសហគមន៍

Mercy Housing ប្តេជ្ញាចិត្តក្នុងការរួមបញ្ចូលសហគមន៍មូលដ្ឋានទៅក្នុងដំណើរការអភិវឌ្ឍន៍តាមរយ:មធ្យោបាយជាច្រើន រួមមានការជួបប្រជុំជាមួយអ្នករស់នៅជិតខាង សមាគមក្នុងតំបន់ និងថ្នាក់ដឹកនាំមូលដ្ឋាន ក៏ដូចជាការជួបប្រជុំជាសាធារណ: និងការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរ និង តាមរយ:អេឡិចត្រូនិចជាទៀតទាត់។ ដោយគោរពទៅតាមគោលការណ៍រក្សាគម្លាតសង្គមពាក់ព័ន្ធនឹង COVID-19, Mercy Housing មិនមានគម្រោងធ្វើការជួបប្រជុំ ឬប្រាស្រ័យទាក់ទងដោយផ្ទាល់នោះទេ។ ឱកាសនានានឹងត្រូវបានផ្តល់ជូនជាព័ត៌មានសហគមន៍តាមរយ:អេឡិចត្រូវនិចដូចជា អ៊ីមែល និងតាមរយ: គេហទំព័រមនុស្សចាស់នៅទីក្រុងឡុងប៊ិច (Long Beach Senior)៖ longbeachsenior.org.

## អំពី MERCY HOUSING

Mercy Housing California (MHC) គឺជាអង្គការអភិវឌ្ឍន៍លំនៅដ្ឋានមិនរកប្រាក់ចំណេញ ដែលមានមូលដ្ឋាននៅរដ្ឋការលីហ្វ័រញ៉ា ដែលមានបេសកកម្មបង្កើត និងពង្រឹងសហគមន៍ដែលមានភាពវិជ្ជមាន។ Mercy Housing បានបង្កើត និងផ្តល់ជូនលំនៅដ្ឋានដែលមានតម្លៃសមរម្យដល់ពលរដ្ឋកាលីហ្វ័រញ៉ាអស់រយៈពេលជាង 30ឆ្នាំមកហើយ។ សព្វថ្ងៃ MHC មានកម្មសិទ្ធិ និងគ្រប់គ្រងសហគមន៍ចំនួន 143 ដែលមានជាង 9.900គេហដ្ឋាននៅទូទាំងរដ្ឋសម្រាប់មនុស្សជាង 18.000នាក់រស់នៅ។



Mercy Housing Management Group (MHMG) នឹងក្លាយជាភ្នាក់ងារគ្រប់គ្រងអចលនទ្រព្យនេះ និងប្តេជ្ញាផ្តល់សេវាកម្មគ្រប់គ្រងអចលនទ្រព្យប្រកបដោយគុណភាពដែលលើកកម្ពស់ទស្សនៈមួយថា គ្រប់អ្នកស្នាក់នៅទាំងអស់ស័ក្តិសមនឹងទទួលបានការគោរពកិត្តិយស និងទីកន្លែងមួយដែលហៅថាផ្ទះ។ MHC និង MHMG គឺជាសម្ព័ន្ធសាខានៃ Mercy Housing, Inc., ដែលជាអង្គការជាតិមិនរកប្រាក់ចំណេញដែលផ្តល់សេវាកម្មអភិវឌ្ឍន៍ គ្រប់គ្រងលំនៅដ្ឋាន និងសេវាកម្មលំនៅដ្ឋាននានា បង្កើតឡើងដោយក្រុមជំនុំចំនួនប្រាំមួយនៃ Women Religious រួមមាន the Daughters of Charity, the Sisters of Mercy និង the Sisters of St. Joseph of Orange។

MHC ត្រូវបានទទួលស្គាល់ដោយសារការរចនាដ៏ល្អឯកការគ្រប់គ្រងប្រកបដោយគុណភាព និងគំរូនៃការផ្តល់សេវាកម្មដល់មនុស្សចាស់ដោយអង្គការសាធារណៈ និងឯកជនចម្រុះ រួមមាន សម្ព័ន្ធរដ្ឋកាលីហ្វ័រញ៉ាសម្រាប់ពលរដ្ឋអាមេរិកដែលចូលនិវត្តន៍ (the California Alliance for Retired Americans) ស្ថាប័នមនុស្សចាស់ (Institute on Aging) សមាគមផែនការអាមេរិក (American Planning)។

## ទីតាំងអចលនទ្រព្យ MERCY HOUSING CALIFORNIA

### មានការិយាល័យក្នុងតំបន់នៅទីក្រុង Los Angeles, Sacramento និង San Francisco



